អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១៥

សេចក្តីប្រកាសព័ត៌មាន
ពិធីចែកសៀវភៅសាលក្រមសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះសាលាដំបូង

ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងចែកសៀវភៅសាលក្រមសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះសាលាដំបូងដល់និស្សិតប្រមាណ ៣០០ នាក់ មកពីសាកលវិទ្យាល័យនានានៅរាជធានីភ្នំពេញ ***នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០១៥ នៅសាលសវនាការរបស់ អ.វ.ត.ក វេលាម៉ោង ៩ ព្រឹក***។

ពិធីចែកសៀវភៅនេះនឹងប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក។ ក្នុងឱកាសនោះ ក៏មានកម្មវិធី សំណួរ-ចម្លើយ រវាងវាគ្មិន និងអ្នកចូលរួមទាក់ទងនឹងដំណើរវិវឌ្ឍន៍ចុងក្រោយរបស់ អ.វ.ត.ក ផងដែរ។

ពិធីនេះគឺជាការចាប់ផ្តើមចែកសៀវភៅសាលក្រមនៃសំណុំរឿង ០០២/០១ ទៅកាន់រាជធានី-ខេត្តទាំង ២៥ ក្រសួង ស្ថាប័ន សាកលវិទ្យាល័យ សង្គមស៊ីវិល និងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងគោលបំណងលើកទឹកចិត្តឱ្យមានការសិក្សាបន្ថែម និងស្វែងយល់ឱ្យកាន់តែច្បាស់ពីសំណុំរឿង ០០២/០១។

សៀវភៅសាលក្រមសំណុំរឿង ០០២/០១ កម្រាស់ ៩៨១ ទំព័រចំនួន ៤៥០០ ក្បាលត្រូវបានបោះពុម្ពជាភាសាខ្មែរ។ សាលក្រមទាំងបីភាសា (ខ្មែរ អង់គ្លេស និងបារាំង) អាចទាញចេញពីគេហទំព័ររបស់ អ.វ.ត.ក **http://www.eccc.gov.kh/document/court/30547**

តំណាងប្រព័ន្ធផ្សព្វផ្សាយដែលមានបំណងចូលរួមក្នុងកម្មវិធីនេះ សូមអញ្ជើញមកអ.វ.ត.ក ឱ្យបានមុន ម៉ោង ៨:៤៥ នាទីព្រឹក។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

លោក ឡាស អូលសិន
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org